ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
លេខ...៣.០.៦៥...
ថ្ងៃទី..៣០...០៥...១១
ម៉ោង..........

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៩៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់ដែនព្រៃលិចទឹកចំនួន ៦៤៧.៤០៦ ហិកតា ស្ថិតនៅក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ( ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ )

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងដំបន់ជីវមណ្ឌលបឹងទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពី ការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពី ការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ស្តីពី ការបង្កើតអាជ្ញាធរទន្លេសាប
- បានឃើញការចាំបាច់របស់រាជរដ្ឋាភិបាល

# ស ម្រេ ច

**មាត្រា ១ :** ត្រូវបានកំណត់ដែនព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាប ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ ដែលមានផ្ទៃសរុបចំនួន ៦៤៧.៤០៦ ហិកតា រួមមាន ៨០២ ចំណុច ដូចមានក្នុងឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យនេះ ។

**មាត្រា ២ :** ផែនទីបង្ហាញទីតាំងដែនព្រៃលិចទឹក (ដោយមានភ្ជាប់ជូនទាំងនិយាមកា) ក្នុងខេត្តទាំងប្រាំមួយខាងលើ ជាឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣ :** អំពីភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវ លើការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹក :

- អភិបាល នៃគណៈអភិបាលខេត្តទាំងប្រាំមួយជុំវិញបឹងទន្លេសាប រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ មានភារកិច្ច កាតព្វកិច្ច និងការទទួលខុសត្រូវ លើការគ្រប់គ្រង ការការពារ និងការថែរក្សាដែនព្រៃលិចទឹក និងព្រៃលិចទឹក ដូចខាងក្រោម :
  - ១- មានភារកិច្ចគ្រប់គ្រងដោយផ្ទាល់ លើដែនព្រៃលិចទឹកដែលមាននៅក្នុងខេត្តនីមួយៗ
  - ២- មានកាតព្វកិច្ចការពារឱ្យខាងតែបាននូវដែនព្រៃលិចទឹក និងព្រៃលិចទឹកដែលមាននៅក្នុងខេត្តនីមួយៗ
  - ៣- ការបាត់បង់ដែនព្រៃលិចទឹក និងព្រៃលិចទឹក ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចនៃខេត្តណា គណៈអភិបាលនៃខេត្តនោះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខរាជរដ្ឋាភិបាល ។
- រដ្ឋបាលជលផល ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំលើសកម្មភាពថែរក្សា ការពារដែនព្រៃលិចទឹក និងព្រៃលិចទឹករបស់អាជ្ញាធរខេត្តទាំង ០៦ ខាងលើ និងត្រូវចាត់វិធានការតាមច្បាប់ជាបន្ទាន់ ក្នុងករណីពិនិត្យឃើញថា មានសកម្មភាពដែលនាំឱ្យប៉ះពាល់ដល់ដែនព្រៃលិចទឹក និងព្រៃលិចទឹក ។
- អាជ្ញាធរទន្លេសាបមានភារកិច្ចធ្វើអធិការកិច្ចលើគ្រប់សកម្មភាពពាក់ព័ន្ធនឹងដែនព្រៃលិចទឹក និងព្រៃលិចទឹក និងត្រូវធ្វើសេចក្តីរាយការណ៍ពីសកម្មភាពទាំងនោះ ជូននាយករដ្ឋមន្ត្រី ដើម្បីមានវិធានការសម្រេច ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានអាជ្ញាធរទន្លេសាប រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិ៣ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

---

លេខ៣៧១ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងបញ្ជូនមក:

-ឯកឧត្តម ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ឯកឧត្តម លោកទីប្រឹក្សាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

« ដើម្បីជូនជ្រាប »

-ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-លោកប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ

« ដើម្បីផ្សព្វផ្សាយ និងមុខការ »

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ៧ ឆ្នាំ ២០១១

ត.ប រដ្ឋមន្ត្រី

អគ្គលេខាធិការ

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ